**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល**
**លេខ: ០៦៦/២២.......អអរ**

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពី "វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និង ទិសដៅការងារបន្ត របស់រដ្ឋបាលខេត្តឧត្តរមានជ័យ"

ព្រឹកថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅការងារបន្ត របស់រដ្ឋបាលខេត្តឧត្តរមានជ័យ»** ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្តម ស៊ី ប្រាសិទ្ធ ប្រធានក្រុមប្រឹក្សាខេត្ត**
- **លោក ម៉ាន ម៉ិក មេឃុំគោកខ្ពស់ ស្រុកបន្ទាយអំពិល**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងបំផុស និងបង្ហាញជាសាធារណៈ នូវយន្តការអនុវត្តគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ជាប្រវត្តិសាស្ត្ររបស់កម្ពុជា និងផ្សព្វផ្សាយពីសមិទ្ធផល ដែលថ្នាក់មូលដ្ឋានខិតខំប្រឹងប្រែងបំពេញការងារសម្រេចបាន ក្នុងកិច្ចរក្សាបាននូវការជឿទុកចិត្ត ចូលរួម និងគាំទ្រពីប្រជាពលរដ្ឋ តាមយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**។

## I. សេចក្តីផ្តើម

ខេត្តឧត្តរមានជ័យ មានក្រុង១ ស្រុក៤ ដែលចែកចេញជា ២៤ឃុំ ស្មើនឹង ៣០៤ភូមិ។ ខេត្តមានប្រជាជនសរុបចំនួន ៦៤,៦៥៦គ្រួសារ ស្មើនឹង ២៦៤,៩៦៩នាក់ ក្នុងនោះ ប្រជាពលរដ្ឋ ៧៥,៥% ជាកសិករ។ ខេត្តមានច្រកទ្វារព្រំដែនអន្តរជាតិ ចំនួន៣គឺ ច្រកជាំ ច្រកអូរស្មាច់ និងច្រកជប់គគីរ។

## II. វឌ្ឍនភាពការងារសំខាន់ៗ

### ❖ ក្រុមប្រឹក្សាខេត្ត

ក្រុមប្រឹក្សាខេត្តឧត្តរមានជ័យ មានសមាជិកចំនួន ១៩រូប ស្រី៥រូប។ ដោយផ្អែកលើតួនាទី និងភារកិច្ចដែលរាជរដ្ឋាភិបាលប្រគល់ជូន ក្រុមប្រឹក្សាខេត្ត សម្រេចបាននូវវឌ្ឍនភាពសំខាន់ៗ ដូចជា៖

- បានជំរុញ និងគាំទ្រដល់ដំណើការអភិវឌ្ឍតាមរយៈយន្តការអនុម័ត ជំរុញ និងតាមដានតាមរយៈកិច្ចប្រជុំសរុបចំនួន ៤៧លើក ការចុះធ្វើវេទិកាសាធារណៈ ដើម្បីទទួលយកសំណើសំណូមពរ និងបញ្ហាប្រឈមរបស់ប្រជាពលរដ្ឋ មកធ្វើការដោះស្រាយជូន។
- បានរៀបចំក្រុមការងារ ដើម្បីទទួលជួបប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ និងតាមដានការអនុវត្តការងារ នៅមូលដ្ឋានក្រុង ស្រុក និងមន្ទីរអង្គភាពនៅក្នុងខេត្ត។
- បានបង្កើតនូវការិយាល័យប្រជាពលរដ្ឋ ដែលមានតួនាទីទទួលពាក្យបណ្ដឹងតវ៉ា និងដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងភាពមិនប្រក្រតីរបស់មន្ត្រីរដ្ឋបាលខេត្ត។

### ❖ ឃុំគោកខ្ពស់ ស្រុកបន្ទាយអំពិល

វឌ្ឍនភាពសំខាន់ៗ ដែលក្រុមប្រឹក្សាសង្កាត់សម្រេចបានរួមមាន៖

- បានកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវសរុបមាន ៣៨ខ្សែ ប្រវែងសរុប ៧៥,២៧៨ម៉ែត្រ ដោយប្រើប្រាស់មូលនិធិឃុំ មូលនិធិរដ្ឋបាលខេត្ត និងមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត និងបានកសាងទំនប់ទឹក ទ្វារទឹក ប្រឡាយទឹក និងបង្ហៀរទឹក សរុប ១០ខ្សែ ដែលទទួលបានការគាំទ្រពីមន្ទីរធនធានទឹក និងឧតុនិយមខេត្ត មូលនិធិឃុំ អង្គការដៃគូ ព្រមទាំងសប្បុរសជននានា។
- បានជីកស្រះចំនួន ០១កន្លែង គាំទ្រដោយអង្គការស៊ីជូ និងស្ដាស្រះចំនួន ០២កន្លែង ជាមូលនិធិឃុំ និងមន្ទីធនធានទឹក បានផ្តល់ផ្តល់ធុងត្រងទឹកដល់ប្រជាពលរដ្ឋក្រីក្រ ចំណុះ ៥០០លីត្រ ចំនួន ៧៥គ្រួសារ, ធុងចម្រោះទឹកស្អាតនៅទូទាំឃុំ និងធុងចម្រោះទឹកស្អាត មានចំណុះ ១,៥០០លីត្រ នៅតាមសាលារៀនចំនួន ០៥សាលា និងផ្តល់អាងត្រងទឹកភ្លៀងជូនប្រជាពលរដ្ឋក្នុងភូមិគោលដៅចំនួន ១០ភូមិ ស្មើនិង ១៤៩ខ្នងផ្ទះ និងធុងចម្រោះ ចំនួន ៦៣ខ្នងផ្ទះ ដែលជាជំនួយរបស់អង្គការដៃគូ មូលនិធិឃុំ និងប្រជាពលរដ្ឋនៅក្នុងឃុំ។
- បានចុះផ្សព្វផ្សាយពីវិធានការទប់ស្កាត់ និងការរីករាលដាលនៃជំងឺកូវីដ-១៩ តាមភូមិនីមួយៗ និងជំរុញឱ្យប្រជាពលរដ្ឋមកទទួលវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដោយបានសម្រេច ៨៧.៧១% នៃប្រជាពលរដ្ឋសរុប និងបានផ្តល់ថវិកាដល់ចាស់ជរាគ្មានទីពឹង និងគ្រួសារក្រីក្រ ក្នុងឡុងពេលការរីករាលដាលជំងឺកូវីដ-១៩។

៣

- បានសហការជាមួយអង្គការដៃគូ ដោយបានផ្តល់សម្ភារៈបង្គន់អនាម័យជូនប្រជាពលរដ្ឋនៅតាមខ្នងផ្ទះ ជាលទ្ធផលនៅឃុំគោកខ្ពស់ សម្រេចបាន ៩៥% ដែលប្រជាពលរដ្ឋមានបង្គន់អនាម័យប្រើប្រាស់។

## III. ទិសដៅការងារបន្ត

### ❖ ក្រុមប្រឹក្សាខេត្ត

ក្រុមប្រឹក្សាខេត្ត បានដាក់ចេញនូវទិសដៅការងារចាំបាច់មួយចំនួនដូច ខាងក្រោម៖

- បន្តរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់
- បន្តគាំទ្រការងារអភិវឌ្ឍន៍ខេត្ត ដោយអនុលោមតាមកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល
- បន្តពង្រឹងអង្គភាពច្រកចេញ-ចូលតែមួយ តាមយន្តការការិយាល័យប្រជាពលរដ្ឋ ក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ
- បន្តពង្រឹងគណៈកម្មការទាំង៣ របស់ក្រុមប្រឹក្សាខេត្ត ក្នុងការអនុវត្តតួនាទី និងភារកិច្ច
- បន្តពង្រឹងការិយាល័យប្រជាពលរដ្ឋ ឱ្យខិតខំដោះស្រាយបណ្តឹង និងវិវាទក្រៅប្រព័ន្ធតុលាការ
- បន្តចូលរួមអនុវត្តគោលនយោបាយយុទ្ធសាស្ត្រចតុកោណ។

### ❖ ឃុំគោកខ្ពស់ ស្រុកបន្ទាយអំពិល

- បន្តខិតខំប្រឹងប្រែងអនុវត្តការងារដែលនៅសេសសល់ ឱ្យសម្រេចបាន
- បន្តអនុវត្តការងារដូចជា ផ្នែកសេវាសង្គមបំរើប្រជាពលរដ្ឋ សេវាសាធារណៈ ពង្រឹងការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការឱ្យមានតម្លាភាព និងប្រសិទ្ធភាព
- បន្តខិតខំគៀងគរដៃគូ អ្នកវិនិយោគ និងសប្បុរសជនដើម្បីចូលរួមអភិវឌ្ឍន៍នៅក្នុងមូលដ្ឋាន
- បន្តអប់រំប្រជាពលរដ្ឋអំពីច្បាប់ចរាចរផ្លូវគោក ការធ្វើចំណាកស្រុកខុសច្បាប់
- បន្តអភិវឌ្ឍន៍ផ្លូវក្រាលគ្រួសក្រហម ឱ្យទៅជាផ្លូវបេតុងគ្រប់ផ្លូវ។

## IV. សម្គាល់

រដ្ឋបាលខេត្តឧត្តរមានជ័យ បានចុះអប់រំ និងផ្សព្វផ្សាយនៅតាមខ្នងផ្ទះ អំពីការប្រកបរបរការងារតាមវិស័យផ្សេងៗនៅក្នុងខេត្ត ជាពិសេសគឺវិស័យកសិកម្ម ដោយមន្ទីរកសិកម្មខេត្ត បានអប់រំ បណ្តុះបណ្តាលជំនាញកសិកម្មដូចជា បច្ចេកទេសចិញ្ចឹមសត្វ ការដាំដំណាំរួមផ្សំ និងស្វែងរកទីផ្សារជូនប្រជាពលរដ្ឋ ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន បង្កើនចំណូលជូនប្រជាពលរដ្ឋ កាត់បន្ថយភាពក្រីក្រ ពិសេសកាត់បន្ថយការធ្វើចំណាកស្រុក និងលួចឆ្លងដែនខុសច្បាប់។ ៕

ថ្ងៃព្រហស្បតិ៍ ៩កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២